សុន្ទរកថារបស់ **ឯកឧត្តម គូម៉ាម៉ារូ យូជិ** ឯកអគ្គរាជទូតវិសាមញ្ញ
និងពេញសមត្ថភាព របស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ
សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ
១០ មិនា ២០១៦

- **សូមគោរព លោក អ៊ុច ហ៊ីង ប្រធានមជ្ឈមណ្ឌលសេវាបច្ចេកទេសសម្រាប់ប្រព័ន្ធស្រោចស្រព និងឧតុនិយម នៃក្រសួងធនធានទឹក និងឧតុនិយម**
- **សូមគោរព លោក ឡុង ផលគុណ ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្តបាត់ដំបង**
- **សូមគោរព លោក ពឹង ទ្រីដា ប្រធានមន្ទីរកសិកម្មខេត្តព្រះវិហារ**
- **សូមគោរព លោក គឹម សាវុធ ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្តស្វាយរៀង**
- **សូមគោរព អស់លោក លោកស្រី!**

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយ ដើម្បីប្រារព្ធពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិចំនួនបីរួមមាន "គម្រោងស្តារឡើងវិញនូវប្រព័ន្ធធារាសាស្ត្រប្រឡាយយោធាក្នុងខេត្តបាត់ដំបង" "គម្រោងសាងសង់មជ្ឈមណ្ឌលសហគមន៍កសិកម្មក្នុងខេត្តព្រះវិហារ" និង"គម្រោងស្តារឡើងវិញនូវប្រព័ន្ធធារាសាស្ត្រប្រឡាយទំនប់លោកក្នុងខេត្តស្វាយរៀង" ។

គម្រោងទីមួយនេះ ផ្តល់ជូនសម្រាប់ពង្រីកផ្ទៃដីដាំដុះនៅក្នុងស្រុកថ្មគោល ខេត្តបាត់ដំបង ដែលមានថវិកាសរុប ៨៩,៣៩២ដុល្លារអាមេរិក។ គម្រោងនេះរួមមាន៖ ការស្តារប្រឡាយ១ខ្សែប្រវែង១,៤០០ម៉ែត្រ ការសាងសង់សំណង់ក្បាលប្រឡាយ១កន្លែង និងសំណង់ស្ពាក់ទឹកលើប្រឡាយ១កន្លែង។ យើងរំពឹងថា ប្រជាកសិករប្រមាណជា៧០០នាក់នឹងទទួលបានទឹកស្រោចស្រពលើដីស្រែរបស់ពួកគេកាន់តែច្រើន បន្ទាប់ពីគម្រោងនេះត្រូវបានបញ្ចប់។

គម្រោងទីពីរនេះ ផ្តល់ជូនដើម្បីជួយដល់មន្ទីរកសិកម្មខេត្តសម្រាប់ការសាងសង់មជ្ឈមណ្ឌលសហគមន៍កសិកម្មចំនួន៣កន្លែង ក្នុងខេត្តព្រះវិហារ ដែលមានថវិកាសរុប៨៤,៦៦២ដុល្លារអាមេរិក។ គម្រោងនេះ នឹងធ្វើការសាងសង់មជ្ឈមណ្ឌលសហគមន៍កសិកម្មចំនួន៣ ព្រមទាំងផ្តល់នូវម៉ាស៊ីនកសិកម្មជាច្រើនគ្រឿងរួមមាន៖ គោយន្តចំនួន៣គ្រឿង ម៉ាស៊ីនបោកស្រូវចំនួន២គ្រឿង ម៉ាស៊ីនបោកសណ្តែកចំនួន១គ្រឿង និងឡសម្ងួតស្រូវ១គ្រឿង ដែលនឹងផ្តល់ជូនដល់សហគមន៍កសិកម្មចំនួន៣។ តាមរយៈសហគមន៍កសិកម្មទាំងបីនេះ យើងសង្ឃឹមថា ប្រជាកសិករប្រមាណជា ៨៨០នាក់ នឹងទទួលបានអត្ថប្រយោជន៍ពីគម្រោងនេះ។

គម្រោងទីបីនេះ ផ្តល់ជូនសម្រាប់ពង្រីកផ្ទៃដីស្រោចស្រពនៅក្នុងស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង ដែលមានថវិកាសរុបចំនួន៨៩,៦០១ដុល្លារអាមេរិក។ គម្រោងនេះរួមមាន៖ ការស្តារប្រឡាយមេ១ខ្សែប្រវែង១,៤២០ម៉ែត្រ និងសំណង់ស្ពាក់ទឹក១កន្លែង។ យើងសង្ឃឹមថាគម្រោងនេះ នឹងជួយសម្រួលដល់ការទទួលបានទឹកស្រោចស្រពសម្រាប់ដីស្រែរបស់ប្រជាកសិករប្រមាណជា ១,៦៧០នាក់ បន្ទាប់ពីគម្រោងនេះត្រូវបានបញ្ចប់។

រដ្ឋាភិបាលជប៉ុន បាននឹងកំពុងបន្តផ្តល់ការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់ប្រជាជនកម្ពុជា តាមរយៈការគាំទ្រនូវគម្រោងអភិវឌ្ឍជាច្រើន។ គម្រោងនៅក្នុងវិស័យកសិកម្មទាំងនោះរួមមាន ការស្តារឡើងវិញនូវប្រព័ន្ធធារាសាស្រ្ត និងការលើកស្ទួយសហគមន៍កសិកម្មជាដើម។ គម្រោងទាំងបីនេះ ធ្វើឡើងតាមគោលការណ៍នៃយុទ្ធសាស្រ្តផ្តល់ជំនួយរបស់ជប៉ុនសម្រាប់កម្ពុជា និងស្របតាមទស្សនៈនៃផែនការជំនួយឧបត្ថម្ភឥតសំណងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ ដើម្បីលើកស្ទួយសន្តិសុខមនុស្សជាតិសម្រាប់ប្រជាជនងាយរងគ្រោះផងដែរ។

ខ្ញុំសង្ឃឹមថា គម្រោងទាំងបីនេះ ដែលបានចុះកិច្ចសន្យាផ្តល់ជំនួយនៅថ្ងៃនេះ នឹងត្រូវបានអនុវត្តយ៉ាងរលូន និងប្រកបដោយប្រសិទ្ធិភាពខ្ពស់ជាមួយនឹងដៃគូររបស់យើង។ ខ្ញុំសង្ឃឹមថា សំណង់ខាងលើនេះ នឹងត្រូវបានថែទាំយ៉ាងត្រឹមត្រូវ ដើម្បីអោយប្រជាជនកាន់តែច្រើនអាចទទួលបានអត្ថប្រយោជន៍ពីគម្រោងទាំងនេះ។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមថា គម្រោងទាំងនេះ នឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពដែលមានរួចមកហើយរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។

**សូមអរគុណ!**